# របាយការណ៍
# ស្តីពី
# សកម្មភាពការងារប្រចាំខែមេសា ឆ្នាំ២០១០
# របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
# និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុង ខែមេសា ឆ្នាំ២០១០ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិដោយមានអគ្គលេខាធិការដ្ឋានជាអង្គភាពប្រតិបត្តិ បានដំណើរការការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម :

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-ផ្ញើលិខិតលេខ ០១៥/១០ លស.កកចយ ចុះថ្ងៃទី៣០ខែមីនា ឆ្នាំ២០១០ សំណើសុំជួបចូលជួបពិភាក្សាស្វែងយល់ពីការអនុវត្តកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ

-ផ្ញើលិខិតលេខ ០១៦/១០ លស.កកចយ ចុះថ្ងៃទ៣០ ខែមីនា ឆ្នាំ២០១០ សំណើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិ ដើម្បីទៅចូលរួមអង្គវិប្បនាសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះ (TWG Rtreat) រយៈពេលពីរថ្ងៃ

-ផ្ញើលិខិតលេខ ០១៧/១០ លស.កកចយ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០ ជូនឯកឧត្តម ជីវ កេង ប្រធានសាលាដំបូងរាជធានីភ្នំពេញ នូវសេចក្តីព្រាងចុងក្រោយបង្អស់នៃអនុក្រឹត្យ ស្តីពីរដ្ឋបាលសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា

-ផ្ញើលិខិតលេខ ០១៨-១៩/១០ លស.កកចយ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១០ សំណើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធ

យុត្តិធម៌ដើម្បីចុះទៅធ្វើកិច្ចប្រជុំជាមួយតុលាការខេត្តកំពង់ចាម និងខេត្តមណ្ឌលគិរី ដើម្បីធ្វើការ វាយតម្លៃការចំណាយដំណើរការរឿងក្តី ព្រហ្មទណ្ឌ ក្នុងមួយករណី។

-ផ្ញើលិខិតលេខ ០២០/១០ លស.កកចយ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ ផ្ញើជូនស្ថាប័នពាក់ព័ន្ធ សំណើសុំចាត់តាំងតំណាង ០១រូប ដើម្បីចូលរួមក្នុងក្រុមការងារតាក់តែងកម្រងពតិមានសេវាសាធារណៈ (ចង្កោមទី៣ ពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល)

-ទទួលលិខិតលេខ ១៤៨ លអជ.រប ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការបង្កើតប្រៃសណីយ៍កម្ពុជាជាគ្រឹះស្ថានសាធារណៈ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១០

-ទទួលលិខិតលេខ ១៤៩ លអជ.រប ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើមីពិភាក្សាលើសេចក្តីព្រាងអនុក្រឹ្យ ស្តីពីការរៀបចំសមាសភាព និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាសកម្មភាពជនពិការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១០

-ទទួលលិខិតលេខ ១៣៩ លអជ.រប ចុះថ្ងៃទី០១ មេសា ឆ្នាំ២០១០ ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវមន្ទីរពេទ្យសាកលវិទ្យាល័យអន្តរជាតិ សែន សុខ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១០ នៅសង្កាត់ភ្នំពេញថ្មី ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ

-ទទួលលិខិតលេខ ៤១៥ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ពីទីស្តីការគណៈរដ្ឋមន្ត្រីសំណើបំពេញ និងផ្ញើត្រឡប់មកវិញនូវកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) បីឆ្នាំរំកិល ២០១១-២០១៣

-ទទួលលខិត Ref:00048421 ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០ ស្តីពី: Invitation to prestentation of the Final Evaluation of the Access to Justice Project

- ទទួលលិខិតលេខ ១៦០ លអជ.រប ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១០ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រកាស និងប្រគល់សមាជិកពេញសិទ្ធិ នៃរាជបណ្ឌិសភាកម្ពុជា ជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិត ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ ពីអង្គការ យូអិនឌីភី ស្តីពីការអញ្ជើញចូលរួមប្រជុំគម្រោងសិទ្ធិទទួលបានយុត្តិធម៌ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ នៅសណ្ឋាគារ អ៊ីមភើរៀល Ballroom 2

-ទទួលលិខិតលេខ ១៣៧ លអជ.រប ចុះថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១០ អញ្ជើញចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការអនុវត្តន៍ច្បាប់ ស្តីពីជីវសុវត្ថិភាពដែលនឹង ប្រព្រឹត្តទៅនៅថ្ងៃអង្គារ៍ទី០៦ ខែមេសា ឆ្នាំ២០១០

## ខ. ការងារកំណែទម្រង់

-អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើការប្រជុំផ្ទៃក្នុងក្រោមអធិបតីភាព ឯកឧត្តម ស៊ុយ ម៉ុងលាង អគ្គលេខាធិការ ដើម្បីពិភាក្សាផ្តល់យោបល់ទៅលើកិច្ចប្រជុំ (CDCF)

រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលទាក់ទងប្រធានបទសំខាន់ៗៈ ១-ការប្រឆាំងអំពើពុករលួយ ២-កំណែទម្រង់រដ្ឋបាល ៣-កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការធ្វើផែនការយុទ្ធសាស្ត្ររបស់អគ្គលេខាធិការដ្ឋាន កាលពីថ្ងៃទី ២១ ខែមេសា ឆ្នាំ២០១០

-ប្រជុំក្រុមការបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១០ ជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូភិវឌ្ឍន៍ ព្រមទាំងម្ចាស់ជំនួយ

-ចុះជួបរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១០ ជួបក្រសួងយុត្តិធម៌ នាថ្ងៃទី៥ ខែមេសា ក្រសួងមហាផ្ទៃនៅថ្ងៃទី២១ ខែមេសា និងចុះទៅជួបតុលាការខេត្តកំពង់ចាមនៅថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០១០ ដើម្បីស្វែងយល់អំពីការងារមួយចំនួនពាក់ព័ន្ធដល់ការពិនិត្យឡើងវិញនូវកម្មវិធីសកម្មភាពសម្រាប់ អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ និងការប៉ាន់តម្លៃសម្រាប់ការអនុវត្តគម្រោងជាអាទិភាពរបស់ **កកចយ**

## គ. ផ្សេងៗ

-ចូលរួមប្រជុំអន្តរក្រសួងផ្សេងៗ និងចូលរួមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

-ចូលរួមក្នុងអង្គវិបស្សនាសម្រាប់ក្រុមការងារបច្ចេកទេសចម្រុះ (TWGs Reatreat )រយៈពេល២ថ្ងៃ (ថ្ងៃទី០៨-០៩ ខែមេសា ឆ្នាំ២០១០ នៅខេត្តសៀមរាប

-ចូលរួមស្តាប់របាយការណ៍បណ្តោះអាសន្នស្តីពីការវាយតម្លៃចុងក្រោយលើគម្រោងសិទ្ធិទទួល បានយុត្តិធម៌ រៀបចំដោយអង្គការយូអិនឌីភី នៅភោជនីយដ្ឋានបៃតងភ្នំពេញ កាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១០

-ចូលរួមធ្វើជាវាគ្មិនកិត្តិយសនៅវិទ្យុ FM១០២ $MH_2$ មណ្ឌលព័ត៌មានស្ត្រីកម្ពុជាទៅលើប្រធានបទៈ តុលាការគំរូ នាថ្ងៃទី២៩ ខែមេសាឆ្នាំ២០១០ ។

## ៣-ទិសដៅអនុវត្តក្នុងខែឧសភា

-បន្តប្រជុំរៀបចំផែនការ ការងារសម្រាប់ផ្នែកផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន

-បន្តការងារបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ បច្ចុប្បន្នកម្ម ២០១០-២០១៣

*រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១០*

**អ្នកធ្វើរបាយការណ៍**

**បានឃើញ និងឯកភាព**

**អគ្គលេខាធិការរង**

ស៊ុន សិរីរ៉ុធ

**សួង លាងហៃ**